ក្រសួងអប់រំ យុវជន និងកីឡា

# ក្ដីប និពន្ធ




២០២៣

ឯកសារបោះពុម្ពនេះ ត្រូវបានរៀបចំចងក្រងឡើងដោយគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP-2) របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រោមកិច្ចសហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីចងក្រងជាឯកសារនវានុវត្តន៍ក្នុងការបង្កើត និងការដឹកនាំក្លឹប។

**រូបភាពក្របសៀវភៅ:** រចនាដោយលោក អឿ សារីន អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

© ក្រសួង អ.យ.ក ២០២៣

# មាតិកា

១. សេចក្តីផ្តើម ............ 1
២. លទ្ធផលសិក្សា ............ 1
២.១. វត្ថុបំណង ............ 1
២.២. លទ្ធផល ............ 1
៣. សម្ភារៈ ............ 2
៤. ដំណើរការអនុវត្ត ............ 2
៤.១. គោលការណ៍រៀបចំ ............ 2
៤.១.១ ការស្ម័គ្រចិត្តៈ ............ 2
៤.១.២ ទំហំៈ ............ 3
៤.១.៣ កម្រិតថ្នាក់គោលដៅៈ ............ 3
៤.១.៤ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិសៈ ............ 3
៤.១.៥ ការបែងចែកភារកិច្ច ............ 4
៤.១.៦ ការកំណត់ផែនការៈ ............ 4
៤.១.៧ ការកំណត់ធនធានៈ ............ 5
៤.២. សកម្មភាពស្នើឡើង ............ 6
៤.២.១ សំណេរច្នៃប្រតិដ្ឋៈ ............ 6
៤.២.២ កំណាព្យៈ ............ 12
៤.២.៣ ទិនានុប្បវត្តិ ............ 14
៤.២.៤ សំបុត្រៈ ............ 15
៤.២.៥ ការបោះពុម្ពៈ ............ 15
៤.២.៦ ការប្រជុំឱ្យតម្លៃស្នាដៃនិពន្ធៈ ............ 15
៤.២.៧ ការឆ្លុះបញ្ចាំងពីដំណើរទស្សនកិច្ចៈ ............ 17
៤.២.៨ ការទំនាក់ទំនងរោងពុម្ពក្នុងមូលដ្ឋានសម្រាប់បោះពុម្ពអត្ថបទរឿងរបស់សិស្ស ............ 17
៤.៣ ការប្រជុំឆ្លុះបញ្ចាំងដើម្បីវាយតម្លៃសកម្មភាពប្រចាំឆ្នាំៈ ............ 17
ឧបសម្ព័ន្ធទី ១ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស ............ 17
ឧបសម្ព័ន្ធទី ២. ការបែងចែកភារកិច្ច ............ 18
ឧបសម្ព័ន្ធទី ៣ ការកំណត់ផែនការ ............ 20
ឧបសម្ព័ន្ធទី ៤ៈ ការកំណត់ធនធាន ............ 21

# បុព្វកថា

ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ការអប់រំបានបណ្តុះនូវមូលធនមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា កាយសម្បទា និងមនសិការវិជ្ជាជីវៈសម្រាប់សង្គមជាតិ។ ក្នុងបរិការណ៍នេះ ក្រសួងអប់រំ យុវជន និងកីឡា មានសេចក្តីសោមនស្សរីករាយក្នុងការចេញផ្សាយនូវសៀវភៅក្លឹបសិក្សាបន្ថែម សម្រាប់ប្រើប្រាស់នៅតាមសាលាមធ្យមសិក្សាសាធារណៈ។

សៀវភៅនេះ មានកម្មវត្ថុសំខាន់ គឺផ្តល់នូវទិដ្ឋភាពថ្មីៗដល់សិស្សានុសិស្សទាំងអស់ ដែលមានតម្រូវការសិក្សាបន្ថែមក្រៅពីការរៀននៅក្នុងថ្នាក់រៀន។ ការបង្កើតក្លឹបសិក្សាបន្ថែម គឺជាការងារស្ម័គ្រចិត្ត ដែលនឹងត្រូវជ្រើសរើសយកទៅអនុវត្តតាមតម្រូវការរបស់សាលាមធ្យមសិក្សាសាធារណៈ ក្នុងការផ្តល់សេវាផ្នែកអភិវឌ្ឍបុគ្គលឱ្យកាន់តែសម្បូរបែបដល់សិស្សតាមប្រធានបទ ដែលសិស្សចាប់អារម្មណ៍។ ការផ្តល់សេវាផ្នែកនេះនឹងមានផលជះដល់ការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់យុវជនកម្ពុជាឱ្យរស់នៅទាន់សម័យកាលជឿនលឿន និងការឈានឡើងរបស់កម្ពុជាជាទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ។

ទន្ទឹមនេះ ការបង្កើតក្លឹបនេះ ទាមទារឱ្យមានក្របខណ្ឌច្បាស់លាស់សម្រាប់ការណែនាំសិស្សរចនាសម្ព័ន្ធប្រតិបត្តិការ តួនាទី និងភារកិច្ច សម្រាប់គ្រូសម្របសម្រួល និងសកម្មភាពគំរូជាក់ស្តែង ដែលពាក់ព័ន្ធទៅនឹងប្រធានបទដែលមាន។ សៀវភៅនេះ បានផ្តល់នូវរចនាសម្ព័ន្ធច្បាស់លាស់ ដល់គ្រូបង្រៀននិងអ្នកគ្រប់គ្រងសាលារៀន ផ្តល់ឱកាសសិក្សាបន្ថែមដល់សិស្ស ដែលចាប់អារម្មណ៍ពិសេសទៅលើជំនាញបន្ថែមណាមួយ។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា សៀវភៅនេះនឹងផ្តល់នូវប្រយោជន៍ដល់មន្ត្រីអប់រំ និងគ្រូបង្រៀននៅមូលដ្ឋានក្នុងការរៀបចំក្លឹបសិក្សាសម្រាប់សិស្ស ប្រកបដោយប្រសិទ្ធភាពតាមជំនាញបន្ថែមនីមួយៗ និងតាមប្រធានបទជាច្រើនដទៃទៀតក្នុងការរួមចំណែកកសាង និងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

១. សេចក្តីផ្តើម

ឯកសារនេះរៀបចំឡើងដើម្បីជួយសិស្សមធ្យមសិក្សាក្នុងការរៀបចំក្លឹប និងផ្តល់ឱកាសសម្រាប់ពួកគេចូលរួមសកម្មភាពក្លឹបនិពន្ធប្រកបដោយភាពច្នៃប្រតិដ្ឋ។ ឱកាសទាំងអស់នេះ មានបំណងផ្តល់នូវបរិយាកាសសិក្សាដល់សិស្ស ដែលមិនទាន់មានការអភិវឌ្ឍផ្នែកបំណិនសំណេរល្អនៅឡើយ។ បញ្ហាទាំងនោះរួមមានកង្វះខាតគំរូសំណេរល្អៗ អ្នកនិពន្ធគំរូ និងបច្ចេកទេសសំណេរដែលផ្តោតលើខ្លឹមសារជាងផ្តោតតែទៅលើអក្ខរាវិរុទ្ធ និងវេយ្យាករណ៍តែមួយផ្នែក។ គេជឿជាក់ថាបរិយាកាសអប់រំនៅក្នុងសាលារៀនបែបនេះ មិនសូវធ្វើឱ្យសិស្សមានការចាប់អារម្មណ៍លើការអភិវឌ្ឍបំណិនសរសេរទេ។ ការបង្កើតក្លឹបនិពន្ធគឺជាវិធីមួយឆ្លើយតបនឹងបញ្ហាខាងលើទាំងនេះ។ ហេតុនេះហើយ ក្លឹបនេះមានគោលបំណងជួយលើកទឹកចិត្តសិស្សឱ្យមានការសរសេរក្នុងបរិយាកាសវិជ្ជមាន។ គេគួរតែលើកទឹកចិត្ត និងជំរុញសមាជិកក្លឹបទាំងអស់ឱ្យចេះពិភាក្សាពីសំណេររបស់ពួកគេប្រកបដោយការស្តាបនា ដែលខុសពីការវាយតម្លៃតាមទម្លាប់ធម្មតានៅក្នុងថ្នាក់រៀន។ ការផ្តល់ព័ត៌មានត្រឡប់គួរធ្វើឡើងដោយមិត្តភក្តិ និងគ្រូសម្របសម្រួលក្លឹប ដែលចុងក្រោយនឹងជួយឱ្យសិស្សចេះស្វ័យវាយតម្លៃដោយខ្លួនឯង។ សកម្មភាពក្លឹបសិក្សាក៏នឹងជួយគាំទ្រ ផ្តល់តម្លៃដល់សំណេររបស់សិស្សតាមរយៈការបោះពុម្ពស្នាដៃសំណេរ ការរៀបចំកម្មវិធីប្រកួតប្រជែង និងការស្វែងរកការបោះពុម្ពតាមសារព័ត៌មាន និងទិនានុប្បវត្តិ។ ជាចុងក្រោយ ក្លឹបនេះនឹងបង្កបរិយាកាសសប្បាយរីករាយដល់សិស្សក្នុងការនិពន្ធនូវអ្វីដែលគួរឱ្យចាប់អារម្មណ៍ដូចជា រឿងប្រលោមលោកថ្មីៗ ការពិភាក្សាឱ្យតម្លៃអំណានជាមួយមិត្តភក្តិ និងមានឱកាសជួបជាមួយអ្នកនិពន្ធនៅក្នុងប្រទេសកម្ពុជា។ គេសង្ឃឹមថា ឱកាសរៀនសូត្របន្ថែមទាំងនេះនឹងធ្វើឱ្យការសិក្សាកាន់តែគួរឱ្យចាប់អារម្មណ៍ស្របតាមបញ្ញត្តិទូទៅនៃកម្មវិធីសាលាកុមារមេត្រី។

★ក្លឹប៖ គឺជាការរួបរួមនៃមនុស្សមួយក្រុមដោយមានគោលដៅរួម ឬមានចំណង់ចំនូលចិត្តដូចគ្នា ដើម្បីធ្វើកិច្ចការរួម និងផលប្រយោជន៍រួមមួយ។

២. លទ្ធផលសិក្សា

**២.១. វត្ថុបំណង**

តាមរយៈការពិភាក្សាបញ្ហាពាក់ព័ន្ធខាងលើ សកម្មភាពក្លឹបនិពន្ធមានវត្ថុបំណងដូចខាងក្រោម៖

- សិស្សមានឱកាសបន្ថែមដើម្បីអភិវឌ្ឍបំណិនសរសេរក្រោមបរិយាកាសបែបស្ថាបនា ដោយគ្មានការស្តីបន្ទោស និងគំរាមកំហែង។
- គ្រូសម្របសម្រួលក្លឹបអាចប្រើឯកសារនេះដើម្បីជួយសិស្សឱ្យចេះរៀបចំសកម្មភាព ដែលផ្តល់បរិយាកាសឱ្យពួកគេអភិវឌ្ឍបំណិនសរសេរ។

**២.២. លទ្ធផល**

ដើម្បីសម្រេចនូវវត្ថុបំណងខាងលើ កម្មវិធីត្រូវអនុវត្តតាមសកម្មភាពដូចខាងក្រោម៖

- អភិវឌ្ឍយន្តការដែលនឹងជំរុញឱ្យសិស្សពង្រឹងនូវសមត្ថភាពសរសេររបស់ពួកគេ
- បង្កើនឱកាសសម្រាប់សិស្សក្នុងការឱ្យតម្លៃអំណានរបស់ពួកគេ
- ជួយសិស្សឱ្យចេះពិភាក្សាអំពីសំណេរ ការបង្ហាញមតិយោបល់ បង្កើតនូវភាពច្នៃប្រតិដ្ឋដែលឆ្លោះ

ទៅរកការបង្កើនចំណេះដឹងផ្ទាល់ខ្លួន។

៣. សម្ភារៈ

សម្ភារៈដែលបានរៀបរាប់នៅខាងក្រោមមិនទាន់មានភាពច្បាស់លាស់នៅឡើយទេ វាអាស្រ័យលើសកម្មភាពដែលសិស្សអនុវត្ត។

- ធនធានឯកសារ (ឧ. រឿងប្រលោមលោកទំនើបៗ ឯកសារទាក់ទងនឹងមេកាព្យ សិល្បៈនៃការតែងនិពន្ធប្រលោមលោក ឬកំណាព្យ...។)
- សម្ភារៈសិក្សា ប៊ិក សៀវភៅកំណត់ត្រាប្រចាំថ្ងៃ/សៀវភៅសរសេរ
- ថវិកាដំណើរការក្លឹបសិក្សា (ប្រសិនមាន) ដើម្បីសម្របសម្រួលសកម្មភាពដែលបានជ្រើសរើស (ឧ. ទស្សនកិច្ចសិក្សា ការថតចម្លងឯកសាររបស់សិស្ស។ល។)
- ប្រាក់ឧបត្ថម្ភសម្រាប់គ្រូសម្របសម្រួលក្លឹប ប្រសិនបើចាំបាច់។

៤. ដំណើរការអនុវត្ត

### ៤.១. គោលការណ៍រៀបចំ

ការបង្កើតក្លឹបនិពន្ធសម្រាប់សិស្ស ត្រូវអនុវត្តតាមគោលការណ៍សំខាន់ៗមួយចំនួន ដែលមានពន្យល់ដូចខាងក្រោម៖

#### ៤.១.១ ការស្ម័គ្រចិត្ត៖

ការចូលរួមក្នុងក្លឹបនិពន្ធ មិនមែនសម្រាប់សិស្សគ្រប់គ្នានោះទេ ហើយអ្នកសម្របសម្រួលក្លឹបទាំងអស់ត្រូវយល់ថា មិនមានការបង្ខិតបង្ខំសិស្សឱ្យចូលរួមក្នុងក្លឹបនេះដែរ។ ពួកគេអាចមានចំណាប់អារម្មណ៍លើក្លឹបផ្សេងៗទៀតដែរ ហើយទាំងអស់នេះគួរអនុវត្តតាមបញ្ញត្តិនៃសាលាកុមារមេត្រី។ ឧទាហរណ៍ ការរៀបចំក្លឹបនិពន្ធអាចត្រូវបានធ្វើឡើង នៅពេលតែមួយដែលក្លឹបផ្សេងទៀតកំពុងត្រូវបានបង្កើតឡើង ពោលគឺប្រហែលជាមានគ្រូណាម្នាក់កំពុងតែបង្កើតក្លឹបសម្រាប់មុខវិជ្ជាផ្សេងៗទៀតដែរ ដូចជាក្លឹបប្រវត្តិសាស្ត្រ ឬក្លឹបសិល្បៈ។ សិស្សត្រូវបានអនុញ្ញាតឱ្យជ្រើសរើសដោយខ្លួនឯងនូវប្រភេទមុខវិជ្ជាដែលពួកគេចង់សិក្សាស៊ីជម្រៅ និងសម្រេចថាតើពួកគេមានពេលវេលា និងចំណាប់អារម្មណ៍យ៉ាងណាក្នុងការចូលរួមក្លឹបនេះ។

ស្រដៀងគ្នានេះដែរ លោកគ្រូ អ្នកគ្រូមិនត្រូវបង្ខំចាត់តាំងឱ្យរៀបចំដឹកនាំក្លឹបនេះទេ។ សេចក្ដីពេញចិត្ត និងការចាប់អារម្មណ៍របស់គ្រូចំពោះការនិពន្ធ ជាប្រការចាំបាច់ណាស់ក្នុងការឈានទៅដល់ភាពជោគជ័យរបស់ក្លឹប។ យើងគួរគិតថា សេចក្ដីពេញចិត្តនោះពិបាកនឹងធានាថាទទួលបាន ប្រសិនបើបង្ខំគ្រូឱ្យអនុវត្តសកម្មភាពនោះ។ ព្រមជាមួយគ្នានេះដែរ គ្រូស្ម័គ្រចិត្តអាចចំណាយពេលផ្ទាល់ខ្លួនរបស់ពួកគេ ដើម្បីធ្វើផែនការសកម្មភាពជាមួយសិស្សដូចជា ការចូលរួមប្រជុំក្រៅម៉ោងសិក្សា និងក្នុងសកម្មភាពទស្សនកិច្ចមូលដ្ឋាន។ សាលារៀន ត្រូវពិចារណាលើបែបបទនៃការផ្ដល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀនដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ថវិកាសកម្មភាពផ្សេងៗទៀតដូចជា ការបំប៉នសិស្សរៀនយឺត និងកម្មវិធីគេហកិច្ចជាដើម។

**៤.១.២ ទំហំ៖**

ក្លឹបនិពន្ធនេះមានភាពងាយស្រួលក្នុងការគ្រប់គ្រង ពេលធ្វើក្នុងសាលារៀនតែមួយ ដោយសារសិស្សនិងគ្រូទាំងអស់ស្ថិតនៅកន្លែងជាមួយគ្នា។ ក្នុងករណីខ្លះសាលារៀនមួយចំនួន ដែលនៅក្បែរគ្នាក្នុងតំបន់គោលដៅក៏អាចចូលរួមក្នុងក្លឹបនិពន្ធនេះបានដែរ ដោយសាលារៀនមធ្យមសិក្សាធនធានដើរតួជាអ្នកសម្របសម្រួល។ ប្រសិនបើមានសាលារៀនមួយចំនួនកំពុងអនុវត្តក្លឹបនិពន្ធ នាយកសាលាទាំងអស់ដែលពាក់ព័ន្ធអាចសម្រេចចិត្តដាក់ធនធានរួមគ្នាធ្វើសកម្មភាពដូចជា ទស្សនកិច្ចសិក្សា ពិព័រណ៍ ស្នាដៃសំណេរ ជាដើមដើម្បីបញ្ចៀសការធ្វើសកម្មភាពជាន់គ្នា។ នាយកសាលាដែលពាក់ព័ន្ធគួរពិនិត្យមើលកម្រិតចំណាប់អារម្មណ៍ចូលរួមក្នុងក្លឹបនិពន្ធតាមសាលារៀន ចម្ងាយរវាងសាលារៀន និងការពេញចិត្តរបស់គ្រូសម្របសម្រួលនៅពេលសម្រេចចិត្តថា តើត្រូវរៀបចំក្លឹបរួមគ្នា ឬធ្វើដាច់ដោយឡែកពីគ្នា។ ក្នុងការអនុវត្តសកម្មភាពរួមគ្នា ត្រូវចាត់ចែងថវិកាមួយចំនួនដែលចាំបាច់សម្រាប់ធ្វើដំណើរសម្របសម្រួលកិច្ចប្រជុំអន្តរសាលារៀន។

**៤.១.៣ កម្រិតថ្នាក់គោលដៅ៖**

ការចូលរួមនៅក្នុងក្លឹបនិពន្ធ គឺជាសកម្មភាពមួយដែលមានភាពល្អប្រសើរ គួរជ្រើសរើសសិស្សដែលមានភាពពេញវ័យ។ នៅពេលសាលាមានបទពិសោធច្រើនក្នុងការរៀបចំក្លឹបនេះហើយ គ្រូប្រហែលជាអាចធ្វើការសាកល្បងរៀបចំសកម្មភាពទាំងឡាយដែលសមស្របទៅនឹងអាយុរបស់សិស្ស។ ទោះជាយ៉ាងក៏ដោយ ជាជំហានដំបូងគេបានណែនាំថាក្លឹបនិពន្ធ ផ្តោតទៅលើសិស្សថ្នាក់ទី ១០ ឬទី ១១ អាស្រ័យទៅលើលទ្ធភាពរបស់គ្រូដែលចាប់អារម្មណ៍ក្នុងការធ្វើការជាមួយសិស្ស។

**៤.១.៤ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស៖**

ការសម្រេចចិត្តរបស់សិស្សក្នុងការចូលរួមក្លឹប គួរតែផ្អែកលើការផ្តល់ព័ត៌មានច្បាស់លាស់ជាមុន។ ក្នុងការវាយតម្លៃចំណាប់អារម្មណ៍របស់សិស្សចូលរួមក្នុងក្លឹប ជាដំបូងគ្រូត្រូវផ្តល់នូវព័ត៌មានណែនាំ ដើម្បីឱ្យសិស្សដឹងថា តើក្លឹបនេះគឺជាអ្វី។ ការតម្រង់ទិសនេះអាចធ្វើឡើងតាមរយៈការពន្យល់ផ្ទាល់មាត់តាមថ្នាក់ ឬការពន្យល់ជាលាយលក្ខណ៍អក្សរដែលបិទផ្សាយជាសាធារណៈ ឬរៀបចំទាំងពីរក៏បាន។ ចំណុចមួយចំនួនដែលត្រូវលើកឡើងនៅក្នុងការណែនាំ គួររួមបញ្ចូលនូវចំណុចសំខាន់ៗដូចខាងក្រោម៖

- ***<u>វត្ថុបំណង៖</u>*** ផ្តល់បរិយាកាសជាវិជ្ជមាន និងគ្មានការគំរាមកំហែងចំពោះការអភិវឌ្ឍបំណិនសរសេរ។
- ***<u>សកម្មភាព៖</u>*** ការចុះតាមមូលដ្ឋាន ការសរសេរកំណត់ត្រាប្រចាំថ្ងៃ ការពិភាក្សាក្រុមអំពីរឿងប្រលោមលោកទំនើបៗ ការបោះពុម្ពផ្សាយអត្ថបទការសែត ការនិពន្ធកំណាព្យ។ល។
- ***<u>ការវាយតម្លៃ៖</u>*** ពុំមានការវាយតម្លៃ ឬការដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ។ សិស្សត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាព ពីព្រោះពួកគេចង់ធ្វើ មិនមែនដោយសារតែគេបង្ខំឡើយ។
- ***<u>ការចូលរួម៖</u>*** សមាសភាពក្លឹបចូលរួមដោយស្ម័គ្រចិត្ត។
- ***<u>ការប្រជុំ៖</u>*** ការប្រជុំគួរធ្វើទៀងទាត់ (អាច២ដង/សប្តាហ៍) ដើម្បីពិភាក្សាផែនការសកម្មភាពដែលបានគ្រោងទុក។ ការប្រជុំត្រូវធ្វើឡើងនៅក្រៅម៉ោងសិក្សា ឬពេលសាលាឈប់សម្រាក។

ផ្អែកតាមសេចក្តីណែនាំនេះ យើងត្រូវសួរសិស្សអំពីចំណាប់អារម្មណ៍របស់ពួកគេក្នុងការចូលរួមក្លឹប តាមរយៈការវាយតម្លៃកម្រិតចំណាប់អារម្មណ៍របស់ពួកគេ។ នៅពេលវាយតម្លៃចំណាប់អារម្មណ៍របស់សិស្ស យើងប្រើទម្រង់នៅក្នុង **ឧបសម្ព័ន្ធទី១**។ ទម្រង់នេះមានសារៈប្រយោជន៍ ពីព្រោះវានឹងត្រូវប្រើជំនួសឱ្យការនិយាយពាក្យ ព្រម ឬ មិនព្រម។ គួរទុកពេលឱ្យសិស្ស ១០ ទៅ ១៥នាទី ដើម្បីពួកគេពិភាក្សា និងសម្រេចចិត្តមុនពេលបំពេញទម្រង់ចំណាប់អារម្មណ៍ និងជូនទម្រង់នោះមកឱ្យគ្រូវិញ។

**៤.១.៥ ការបែងចែកភារកិច្ច**

នៅក្នុងការប្រជុំក្លឹបលើកដំបូង គ្រូដែលមានភារកិច្ចទទួលខុសត្រូវសម្របសម្រួលក្លឹប ត្រូវរៀបចំជ្រើសរើសសមាជិកក្លឹបមួយចំនួនដើម្បីទទួលខុសត្រូវទៅតាមភារកិច្ច។ គ្រូត្រូវរៀបចំបង្កើតរចនាសម្ព័ន្ធក្លឹបតាមរយៈការបោះឆ្នោតជាសម្ងាត់ ឬដោយវិធីលើកដៃ ដើម្បីជ្រើសរើស (១)ប្រធាន (២)អនុប្រធាន និង(៣)ហិរញ្ញិក។ ប្រសិនបើមានសិស្សច្រើននៅក្នុងក្លឹប (ឧ. ១៥នាក់ ឬច្រើនជាងនេះ) រៀបចំបន្ថែមឱ្យមានក្រុមតូចៗក្នុងនោះទៀត ដែលអាចមានសមាជិកពី ៣ ទៅ ៥ នាក់ រួមទាំងប្រធានក្រុមម្នាក់។ ការទទួលខុសត្រូវក្នុងតួនាទីនីមួយៗ ត្រូវបានបង្ហាញនៅក្នុង **ឧបសម្ព័ន្ធទី២**។ គ្រូសម្របសម្រួលក្លឹបត្រូវបង្ហាញដល់សមាជិកក្លឹបទាំងអស់នូវការទទួលខុសត្រូវរបស់ពួកគេម្នាក់ៗ។ ក្នុងជំហានដំបូងនៃសកម្មភាពក្លឹប គ្រូត្រូវមានទំនាក់ទំនងល្អក្នុងការចូលរួមចំណែកជួយដល់សមាជិកក្លឹបដែលបានជ្រើសរើស និងជួយដល់ការបំពេញតាមតួនាទីរបស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ គ្រូសម្របសម្រួលត្រូវបេះផ្ទេរការទទួលខុសត្រូវឱ្យបានច្រើនដល់សិស្ស នៅពេលដែលពួកគេមានបទពិសោធកាន់តែច្រើនក្នុងការបំពេញភារកិច្ច។

**៤.១.៦ ការកំណត់ផែនការ**

កិច្ចការមួយក្នុងចំណោមការងារដំបូងគេដែលក្លឹបត្រូវធ្វើគឺ ការរៀបចំផែនការសកម្មភាពក្លឹបក្នុងរយៈពេល ១ ត្រីមាសម្តង និងលម្អិតផែនការប្រចាំសប្តាហ៍ ដូចត្រូវបានបង្ហាញក្នុង **ឧបសម្ព័ន្ធទី៣**។ មុនពេលបង្កើតផែនការ គ្រូសម្របសម្រួលក្លឹបត្រូវពិនិត្យឡើងវិញនូវសកម្មភាពមួយចំនួនដែលអាច ធ្វើទៅបាន ហើយបង្កើតគម្រោង ១ ឬ ២ ដែលក្លឹបនឹងធ្វើនៅក្នុងពេល១ត្រីមាស។ ឧទាហរណ៍មួយចំនួន ត្រូវបានផ្តល់ឱ្យជាគំរូនៅផ្នែកខាងក្រោម។ ឧទាហរណ៍ ក្លឹបប្រហែលជាចង់សរសេរអត្ថបទខ្លីបែបច្នៃប្រតិដ្ឋពីរមណីយដ្ឋានណាមួយនៅក្នុងតំបន់។ គ្រូត្រូវជួយសម្របសម្រួលសកម្មភាពអំពីរបៀបសរសេរប្រភេទផ្សេងៗនៃអត្ថបទដូចជា ការសរសេរអត្ថបទស្រាវជ្រាវ អត្ថបទកំណាព្យជាដើម មុនពេលរៀបចំទស្សនកិច្ចទៅកាន់រមណីយដ្ឋាននោះ។ គ្រូសម្របសម្រួលក្លឹបត្រូវសម្របសម្រួលសកម្មភាពទាំងឡាយរហូតទាល់តែសិស្សយល់ច្បាស់ពីរបៀបសរសេរ និងអាចអនុញ្ញាតឱ្យពួកគេសរសេរអត្ថបទដោយខ្លួនឯងបាន។ ប្រភេទនៃសកម្មភាពសំណេរត្រូវបានភ្ជាប់ជូននៅក្នុង**ឧបសម្ព័ន្ធទី៥** នៃឯកសារនេះ។ នៅពេលពួកគេបានសរសេរអត្ថបទរួចរាល់ ក្លឹបត្រូវរៀបចំការតាំងពិព័រណ៍នៅក្នុងបណ្ណាល័យ ឬក្នុងថ្នាក់រៀន ព្រមទាំងធ្វើបទបង្ហាញដល់សិស្សផ្សេងទៀត ដែលមិនមែនជាសមាជិកក្លឹប។ សកម្មភាពទាំងអស់នេះត្រូវបានសរសេរឡើងក្នុងផែនការផងដែរ។ ឧទាហរណ៍មួយត្រូវបានផ្តល់ឱ្យនៅក្នុងតារាងខាងក្រោម៖

**តារាងទី១៖ ការកំណត់ផែនការ**

**ត្រីមាសទី១**

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| 1. ការប្រជុំលើកទី ១៖ ការបោះឆ្នោត និងសកម្មភាពនិពន្ធ | x | | | | | | | | | | | |
| 2. ការប្រជុំលើកទី ២៖ សកម្មភាពនិពន្ធ | | X | | | | | | | | | | |
| 3. ការប្រជុំលើកទី ៣៖ សកម្មភាពនិពន្ធ | | | x | | | | | | | | | |
| 4. ដំណើរការទស្សនៈកិច្ច | | | | x | | | | | | | | |
| 5. សកម្មភាពនិពន្ធ | | | | | x | | | | | | | |
| 6. ផែនការតាំងពិព័រណ៌ | | | | | | x | | | | | | |
| 7. រៀបចំការតាំងពិព័រណ៌ | | | | | | | x | | | | | |
| 8. ការតាំងពិព័រណ៌បង្ហាញ | | | | | | | | x | | | | |

**៤.១.៧ ការកំណត់ធនធាន៖**

ដើម្បីឱ្យក្លឹបមានដំណើរការដោយប្រសិទ្ធភាព ក្លឹបត្រូវមានធនធានគាំទ្រ។ ធនធានទាំងនេះ រួមមាន សម្ភាររូបវន្តដូចជា កន្លែងប្រជុំ (ឧ. បណ្ណាល័យ ថ្នាក់រៀនដែលទំនេរ ឬទីធ្លាណាមួយ) សៀវភៅរឿងប្រលោមលោក ក្បួនមេកាព្យ ឬទស្សនាវដ្តី បន្ទប់កុំព្យូទ័រសម្រាប់វាយសំណេរបែបច្នៃប្រតិដ្ឋ ឬធនធានថវិកា។ ធនធានថវិកាត្រូវប្រើសម្រាប់អនុវត្តសកម្មភាពជាក់លាក់ដូចខាងក្រោម៖

- ក្រដាសសម្រាប់កត់ត្រា ឬសរសេររបាយការណ៍ (គ្រប់ក្រុម)
- ក្រដាសផ្ទាំងធំសម្រាប់បង្កើតការតាំងពិព័រណ៌
- ហ្វឹតសម្រាប់រៀបចំការតាំងពិព័រណ៌
- ថវិកាសម្រាប់ការធ្វើដំណើរទស្សនៈកិច្ច
- ម៉ាស៊ីនថតរូបសម្រាប់ថតរូប (អាចប្រើទូរសព្ទឆ្លាតវៃជំនួសតាមស្ថានភាពជាក់ស្តែង)
- ថវិកាផ្សេងៗសម្រាប់គោលបំណងពិសេសផ្សេងៗទៀត
- ផ្សេងៗ

ការផ្តល់ថវិកាគួរតែរៀបចំផែនការដោយគណៈកម្មការសាលា ដែលជាផ្នែកមួយនៃដំណើរការរៀបចំផែនការប្រចាំឆ្នាំ ដែលធ្វើឡើងនៅរៀងរាល់ដើមឆ្នាំ។ ការពន្យល់បកស្រាយអំពីថវិកាមាននៅក្នុង **ឧបសម្ព័ន្ធទី ៤**។

## ៤.២. សកម្មភាពស្នើឡើង

គេអាចរៀបចំសកម្មភាពច្រើនប្រភេទ ដើម្បីបង្កើនការរៀនសូត្ររបស់សិស្ស ដោយមិនចាំបាច់ទាមទារពេលវេលារបស់ពួកគេក្នុងការបំពេញកិច្ចការ ឬពេលវេលារបស់គ្រូសម្របសម្រួលក្នុងការប្រជុំ និងការដាក់ពិន្ទុសិស្សឡើយ។ តាមការពិតអ្នកជំនាញផ្នែកនិពន្ធជាច្រើននាក់យល់ថា សិស្សចេះពីរបៀបនៃការតែងនិពន្ធតាមរយៈការហ្វឹកហ្វាត់សរសេរអត្ថបទវែងៗ ដោយគោរពតាមក្បួនខ្នាតច្បាស់លាស់ ជាជាងការសរសេរអត្ថបទរឿងខ្លីៗ។ ការសរសេរ គឺជាវិធីមួយនៃការរៀនសូត្រ ដែលធ្វើឱ្យសិស្សគិតស្រាវជ្រាវ និងបង្កើតក្តីស្រមៃ។

មានសកម្មភាពសំណេរដែលគួរឱ្យចាប់អារម្មណ៍ជាច្រើនដែលក្លឹបអាចរៀបចំ ហើយធានាថាវាជាសកម្មភាពដ៏ល្អ មានលក្ខណៈវិភាគសម្រាប់សិស្សរៀន។ សកម្មភាពដែលត្រូវបានផ្តល់ឱ្យនៅផ្នែកខាងក្រោម គឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ គ្រូសម្របសម្រួល និងសមាជិកក្លឹប អាចមានគំនិតផ្ទាល់ខ្លួនអំពីអ្វីដែលពួកគេចង់ធ្វើប្រកបដោយលក្ខណៈច្នៃប្រតិដ្ឋតាមរយៈការនិពន្ធ។

### ៤.២.១ សំណេរច្នៃប្រតិដ្ឋ៖

សំណេរដែលមានលក្ខណៈប្រតិដ្ឋ ជាទម្រង់ប្រើដើម្បីបែងចែកការស្រមើស្រម៉ៃជាក់លាក់ ឬសកម្មភាពខុសគ្នានៃការសរសេរដែលមានលក្ខណៈបច្ចេកទេស។ ការប្រើប្រាស់ភាពជាក់លាក់នៃទម្រង់នេះគឺមានចេតនាមួយ ដែលបានរចនាឡើងដើម្បីធ្វើឱ្យការសរសេរ ជាដំណើរការសម្រាប់មនុស្សគ្រប់រូប (គ្រប់វ័យ) និងដើម្បីធានាថាការសរសេរនោះមិនមែនជាទម្រង់សំណេរបែបប្រពៃណី ឬតាមបែបប្រពៃណីកម្រិតទាប (ឧទាហរណ៍ ការសរសេរដោយក្រុមមួយដែលនៅមានកម្រិតការសរសេរពីការពិសោធ ការសរសេរអំពីរឿងប្រតិដ្ឋ) មិនបានដកចេញ ឬត្រូវបានច្រានចោលថាជារឿងតូចតាច ឬមិនសំខាន់នោះទេ។ ដូច្នេះ ការសរសេរប្រកបដោយគំនិតច្នៃប្រតិដ្ឋត្រូវបានរួមបញ្ចូលហើយមិនត្រូវបានកំណត់ថាជារឿងប្រតិដ្ឋ រឿងល្ខោន (សម្រាប់ឆាត ឬអេក្រង់ ) កំណាព្យ ការសរសេរពីអនុស្សាវរីយ៍ រឿងប្រតិដ្ឋ ឬរឿងមិនប្រតិដ្ឋឡើយ។

សម្រាប់សិស្សដែលមិនមានចំណេះដឹងក្នុងការពិសោធ ការស្វែងរកទិន្នន័យក្នុងការសរសេរប្រកបដោយគំនិតច្នៃប្រតិដ្ឋ នឹងដឹងថាត្រូវចាប់ផ្តើមពីកន្លែងណានោះគឺជាបញ្ហាប្រឈម។ មានសារៈសម្រាប់គ្រូសម្របសម្រួលក្នុងការយល់ដឹងអំពីបញ្ហានេះ។ សូមមើលសកម្មភាពខាងក្រោម

## <u>សកម្មភាពសំណេរបែបច្នៃប្រតិដ្ឋ</u>

សម្គាល់៖ ផែនការសកម្មភាពនីមួយៗមានកំណត់ពេលរួចជាស្រេច ប៉ុន្តែត្រូវធានាថាផ្តល់ពេលវេលាឱ្យសិស្សតាមតម្រូវការ។ សិស្សមួយចំនួនអាចត្រូវការពេលវេលាយូរក្នុងការគិត និងបង្ហាញគំនិតរបស់ពួកគេ។ សកម្មភាពទាំងនេះគឺជាមធ្យោបាយរីករាយមួយសម្រាប់បង្កឱ្យសិស្សបញ្ចេញនូវភាពច្នៃប្រតិដ្ឋ ហើយបន្តសកម្មភាពនិពន្ធដោយខ្លួនឯងក្នុងពេលទំនេររបស់ពួកគេ។

<u>1. **ការនិពន្ធពីកំណាប់ដែលបានរកឃើញ**</u>




**វត្ថុបំណង ៖** សកម្មភាពនេះគឺជាវិធីដ៏ល្អមួយឱ្យសិស្សយល់កាន់តែច្បាស់អំពីដំណើរការសំណេរបែបច្នៃប្រតិដ្ឋ។

**សម្ភារ ៖** ហិបដាក់វត្ថុផ្សេងៗ

**ពេលវេលា ៖** ១ – ២ម៉ោង

**ដំណើរការ ៖** ប្រមូលរបស់កំប៉ិចកំប៉ុក ហើយរៀបដាក់ក្នុងថង់ក្រដាសតូចៗ។ អ្នកអាចដាក់អ្វីៗផ្សេងទៀតដូចជាដុំថ្ម ក្រដាសចោលមួយសន្លឹក រោមសត្វមួយ រូបថតរបស់ក្មេងស្រីណាមួយ និងរូបឆ្មៃរបស់នាង ឡេវអាវ និងអ្វីៗផ្សេងៗទៀត។ អ្នកត្រូវមានថង់សម្រាប់សិស្សគ្រប់គ្នា ហើយថង់មួយសម្រាប់សិស្សមួយក្រុម ឬថង់មួយសម្រាប់សិស្សមួយថ្នាក់។

**កិច្ចការ ៖** ហិបមួយដែលអ្នកបានទទួល មានផ្ទុកគ្រឿងរតនសម្បត្តិជាច្រើនដែលត្រូវបានគេទុកឱ្យ។ កិច្ចការរបស់អ្នក គឺត្រូវសរសេររឿងខ្លីមួយដែលពណ៌នាអំពីតួអង្គដែលបានប្រមូលវត្ថុទាំងនោះ ហើយបង្ហាញថាតើហេតុអ្វីបានជាវត្ថុទាំងនោះសំខាន់សម្រាប់តួអង្គនោះ។ តើវត្ថុទាំងនោះមានដំណើររឿងដូចម្ដេច? ហេតុអ្វីបានជាតួអង្គនោះថែរក្សាទុកនូវវត្ថុទាំងនោះ? តើវត្ថុនោះអាចប្រាប់អ្នកអំពីអ្វីខ្លះពីតួអង្គនោះ? តើតួអង្គនោះមានអាយុប៉ុន្មានឥឡូវនេះ ហើយតើគាត់មានអាយុប៉ុន្មានកាលពេលគាត់រើសបានវត្ថុទាំងនោះ? តើអ្នកគិតថាវត្ថុទាំងនោះគឺជារបស់ដែលតួអង្គបានទុកចោលនៅក្នុងជំនាន់របស់គាត់ដែរឬទេ? ចូរសរសេររឿងមួយអំពីវត្ថុទាំងនេះដែលតួអង្គទុកចោល?

## ២. ដំណើររឿងមិនតាមលំដាប់លំដោយ

វត្ថុបំណង ៖ សកម្មភាពនេះគឺជាវិធីដ៏ល្អមួយឱ្យសិស្សយល់កាន់តែច្បាស់អំពីដំណើរការសំណេរបែបច្នៃប្រតិដ្ឋ។

សម្ភារ ៖ បញ្ជីតួអង្គ/ទីកន្លែង/ពេលវេលា/ស្ថានភាព និងបញ្ហាប្រឈម សម្រាប់ជាឯកសារយោងរបស់គ្រូ

ពេលវេលា ៖១ - ២ ម៉ោង

ដំណើរការ ៖ឱ្យសិស្សជ្រើសរើស៣លេខ (ពីលេខ ១ ដល់លេខ ១០)។ លេខនីមួយៗត្រូវគ្នានឹងវត្ថុមួយនៅក្នុងបញ្ជីខាងក្រោម។ លេខទី១ គឺជាតួអង្គសំខាន់នៅក្នុងរឿង លេខទី២ គឺជាទីកន្លែង ។ល។

**កិច្ចការ៖** ចូរសរសេររឿងមួយដោយប្រើតួអង្គ ទីកន្លែង ពេលវេលា និងស្ថានភាពដែលអ្នកបានជ្រើសរើស។ តួអង្គដែលអ្នកបានជ្រើសរើសគួរតែជាតួអង្គឯកនៅក្នុងរឿង ប៉ុន្តែមិនមែនចាំបាច់តែតួអង្គនៅក្នុងរឿងនោះទេ។ ដូចគ្នានេះដែរ ទិដ្ឋភាពភាគច្រើននៃសាច់រឿងកើតនៅកន្លែងដែលអ្នកបានជ្រើសរើស ប៉ុន្តែអ្នកអាចរាប់បញ្ចូលទីកន្លែងផ្សេងៗ ឬបកស្រាយរៀបរាប់ពីទីកន្លែងដែលបានជ្រើសរើសនោះ (ឧ. បំបែកសាច់រឿងទៅជាផ្នែកតូចៗ)។ ស្ថានភាព ឬបញ្ហាប្រឈមដែលអ្នកបានជ្រើសរើសអាចទាក់ទងនឹងតួអង្គឯក ឬតួអង្គឯកអាចសង្កេតនរណាម្នាក់ផ្សេងទៀតដែលមានទំនាក់ទំនងជាមួយនឹងស្ថានភាព ឬបញ្ហាប្រឈមនោះ។ មួយវិញទៀត អ្នកអាចបញ្ចូលជាតុទាំងនេះតាមវិធីណាក៏បាន ដែលអ្នកចង់បាន ឱ្យតែបញ្ចូលចំណុចទាំង៤ខាងលើ។

**ឧទាហរណ៍នៃបញ្ជីលេខ សម្រាប់ជាឯកសារគ្រូ**

**តួអង្គ**

1. ម្ដាយថ្មីម្នាក់
2. អ្នកថតរូបម្នាក់
3. សិស្សដែលទើបបញ្ចប់ថ្នាក់វិទ្យាល័យម្នាក់
4. ម្ចាស់ភោជនីយដ្ឋាន ឬអ្នកគ្រប់គ្រងម្នាក់
5. មនុស្សចម្លែកមកពីអវកាស
6. ក្មេងអនាថាម្នាក់
7. ស្ត្រីអាយុ៩៣ឆ្នាំម្នាក់
8. អ្នកបរិស្ថាននិយមម្នាក់
9. និស្សិតមហាវិទ្យាល័យម្នាក់
10. តន្ត្រីករ Jazz ម្នាក់

**ទីកន្លែង**

1. នៅជិតព្រៃ
2. កន្លែងទទួលភ្ញៀវនៅពិធីមង្គលការ
3. ពិធីជប់លៀងមួយកន្លែង
4. ភោជនីយដ្ឋានមួយកន្លែង
5. ហាងលក់ឥវ៉ាន់
6. ឧទ្យានទីក្រុង
7. យ៉ផ្ទះកសិដ្ឋានចាស់មួយ
8. ប្រឡាយបង្ហូរជាតិពុល
9. បណ្ណាល័យរបស់មហាវិទ្យាល័យ

| |
|---|
| 10. សាលមហោស្រពតន្ត្រី |
| **ពេលវេលា**<br>1. អំឡុងពេលភ្លើងឆេះព្រៃ<br>2. បន្ទាប់ពីវាយគ្នា<br>3. នៅយប់ថ្ងៃប្រលងបញ្ចប់ថ្នាក់វិទ្យាល័យ<br>4. បន្ទាប់ពីហូបអាហាររួច<br>5. ពេលណាមួយក្នុងខែធ្នូ<br>6. យប់ជ្រៅ<br>7. បន្ទាប់ពីមានព្យុះផ្គររន្ទះកើតឡើង<br>8. នៅដើមរដូវរំហើយ<br>9. សប្ដាហ៍ទីមួយនៃឆ្នាំសិក្សា<br>10. នៅពេលប្រគំតន្ត្រី |
| **ស្ថានភាព/បញ្ហាប្រឈម**<br>1. ត្រូវការធ្វើការសម្រេចចិត្តឱ្យបានត្រឹមត្រូវ<br>2. សារភាពអាថ៌កំបាំងដល់នរណាម្នាក់<br>3. មោទនភាពរបស់នរណាម្នាក់បានបង្កឱ្យមានគ្រោះថ្នាក់<br>4. ការស្លាប់បានកើតឡើង<br>5. មាននរណាម្នាក់បានរកឃើញ ឬបាត់អ្វីមួយ<br>6. មនុស្សម្នាក់ជំរុញឱ្យមនុស្សម្នាក់ទៀតធ្វើខុស<br>7. រំលឹកឡើងនូវមធ្យោបាយដែលធ្វើឱ្យអ្វីៗបានផ្លាស់ប្ដូរ<br>8. មនុស្សម្នាក់មានអារម្មណ៍ថាចង់លះបង់<br>9. រឿងគួរឱ្យអាម៉ាស់បានកើតឡើង<br>10. មាននរណាម្នាក់បានឈានដល់គោលដៅដ៏សំខាន់មួយ |

## ៣. សំបុត្រនៅក្នុងដប (A Message in a Bottle)



**វត្ថុបំណង** ៖ សិស្សម្នាក់ៗនឹងបង្កើតសំណេរច្នៃប្រតិដ្ឋពីការធ្វើដំណើរផ្សងព្រេង។

**សម្ភារ** ៖ ផែនទីពិភពលោក សៀវភៅផែនទី ដបដ៏មានគម្រប (មួយសម្រាប់សិស្សម្នាក់ ឬមួយក្រុម សម្រាប់សរសេររឿង ធុងចិញ្ចឹមត្រី ឬអាងទឹក (ប្រសិនបើមាន)

**រយៈពេល** ៖ ១ - ២ ម៉ោង

**ដំណើរការ ៖**

1. ប្រាប់សិស្សថា ពួកគេម្នាក់ៗនឹងសរសេររឿងពីការធ្វើដំណើរផ្សងព្រេងបែបស្រមើស្រមៃមួយ ឬការធ្វើដំណើរមួយដែលបានធ្វើឱ្យគេជាប់នៅលើកោះខ្សាច់។ ចូរពន្យល់ថា ឱកាសតែមួយគត់សម្រាប់ការជួយសង្គ្រោះគឺ សរសេរសារមួយដាក់ចូលក្នុងដប ហើយដាក់ដបបណ្តែតទឹកដោយសង្ឃឹមថានឹងមាននរណាម្នាក់ឃើញវា។
2. បំផុសគំនិតទៅកាន់សិស្សអំពីប្រភេទនៃព័ត៌មាន ដែលពួកគេគួរតែសរសេរបញ្ចូលនៅក្នុងរឿងរបស់ពួកគេ។ ឧទាហរណ៍ ពួកគេអាចចង់ពន្យល់ថាតើពួកគេជានរណា ពួកគេនឹងទៅកន្លែងណា ពួកគេជាប់គាំងនៅពេលណា ពួកគេមកពីណា ហើយតើពួកគេធ្វើដំណើរយ៉ាងដូចម្តេច។ សិស្សគួរតែសរសេរផងដែរនូវព័ត៌មានអំពីថាតើពួកគេនៅឯណា តើកោះនោះយ៉ាងដូចម្តេចដែរ អាកាសធាតុយ៉ាងណា តើសត្វ និងរុក្ខជាតិអ្វីដែលពួកគេបានឃើញ ហើយតើពួកគេរួចផុតជីវិតដោយរបៀបណា។ ចូរកត់ត្រានូវសំណូមពររបស់ពួកគេនៅលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។
3. នៅពេលសិស្សរៀបចំខ្លួនក្នុងការសរសេររួចរាល់ហើយ បង្កើតជាផែនទី ឬសៀវភៅផែនទី ដែលឱ្យពួកគេអាចប្រើប្រាស់បាន។ សិស្សអាចមើលផែនទី ប្រសិនបើពួកគេត្រូវប្រើជាជំនួយក្នុងការធ្វើផែនការពីការធ្វើដំណើររបស់ពួកគេ ឬប្រកបឈ្មោះទីកន្លែងដែលពួកគេចង់សរសេរនៅក្នុងរឿងនោះ។
4. នៅពេលសិស្សសរសេររួច ឱ្យពួកគេដាក់រឿងចូលទៅក្នុងដប ហើយប្រមៀលដបលើតុប្រៀបបីដូចជាទឹកហូរ (ឬធុងអ្វីផ្សេងទៀតដែលអាចប្រើប្រាស់បាន)។
5. បន្ទាប់មកទៀត ឱ្យសិស្សម្នាក់ៗស្ទូច(ចាប់)ដប (មិនមែនជាដប របស់ពួកគេ)ពីក្នុងទឹកហើយអានវាឱ្យលឺៗ។ បន្ទាប់ពីអានចប់រឿងនីមួយៗ សិស្សអាចសង្គ្រោះអ្នកសរសេរសំបុត្របាន ដោយប្រើផែនទី និងព័ត៌មានលម្អិតនៃសាច់រឿងដើម្បីស្វែងរកឱ្យឃើញថា តើមនុស្សនោះបានជាប់គាំងនៅឯណា។

## <u>៤. ទស្សនាវដ្តីអស្ចារ្យ</u>

**វត្ថុបំណង** ៖ ឱ្យសិស្សចេះបង្កើតរឿងដោយប្រើប្រាស់បំណែកអត្ថបទរឿងប្រើទស្សនាវដ្តីជាជំនួយ

**សម្ភារ** ៖

- ទស្សនាវដ្តីចាស់ៗដែលមានរូបភាព/ប្រធានបទផ្សេងៗ
- កាវ ឬស្កុត
- ក្រដាសផ្ទាំងធំ ឬតូចទំហំប៉ុនខិតប័ណ្ណផ្សព្វផ្សាយ
- កន្ត្រៃ

**រយៈពេល** ៖ ១ - ២ម៉ោង

**ដំណើរការ ៖**

1. សិស្សអាចធ្វើការម្នាក់ឯង ជាដៃគូ ឬជាក្រុមតូចៗ

2. អ្នកនិពន្ធ/ក្រុមអ្នកនិពន្ធទទួលសឺមីមួយដែលមានរូបភាពទស្សនាវដ្តីមួយឈុត។ សាច់រឿងមួយត្រូវបង្កើតឡើងដោយប្រើរូបភាពយ៉ាងហោច ៥ (តួអង្គលាយបញ្ចូលគ្នា) ឧ. បុរសវ័យក្មេងទាំងអស់នៅក្នុងរឿង គឺឈ្មោះ វេតនៈ ទោះបីជាពួកគេមានមុខមាត់ខុសគ្នាក៏ដោយ)។
3. ប្រសិនបើមានអ្នកនិពន្ធច្រើន ត្រូវតែចែករំលែកការនិទានរឿងឱ្យបានស្មើៗគ្នា។

**ជម្រើសមួយផ្សេងទៀត**

1. សិស្សអាចធ្វើការម្នាក់ឯង ជាដៃគូ ឬជាក្រុមតូចៗ
2. អ្នកនិពន្ធ/ក្រុមអ្នកនិពន្ធទទួលសឺមីមួយដែលមានរូបភាពទស្សនាវដ្តីមួយឈុត ហើយជ្រើសរើសយករូបភាពគួរឱ្យចាប់អារម្មណ៍ចំនួន ៤-៥ សម្រាប់ប្រើជាការនិទានរឿង។

## ៥. ការនិទានពីទីកន្លែងកាលពីនៅកុមារភាព

**វត្ថុបំណង** ៖ ឱ្យសិស្សចេះបញ្ចូលសំណេរច្នៃប្រតិដ្ឋជាមួយការសរសេរឆ្លុះបញ្ចាំង

**សម្ភារ** ៖ ខ្មៅដៃ និងក្រដាស

**រយៈពេល** ៖ តាមតម្រូវការ

**ដំណើរការ** ៖ ណែនាំឱ្យសិស្សគិតអំពីទីកន្លែងសំខាន់មួយ ឬព្រឹត្តការណ៍មួយកាលនៅកុមារភាព។ សរសេររឿងប្រតិដ្ឋមួយស្តីពី កុមារម្នាក់ដែលតែងទៅកន្លែងនោះ ឬចូលរួមក្នុងព្រឹត្តិការណ៍នេះ ដោយយកគំរូតាម**សៀវភៅកុមារ** ដែលនិយាយពីមនុស្សម្នាក់មានអាយុប្រហាក់ប្រហែលគ្នានៅពេលពួកគេនៅកន្លែងនោះឬក៏ពាក់ពន្ធនឹងព្រឹត្តិការណ៍នោះ។

ដោយសារពួកគេកំពុងសរសេរកំណត់ត្រាពីទីកន្លែង ឬព្រឹត្តិការណ៍ណាមួយនោះ រាល់ព័ត៌មានលម្អិតរបស់គេមិនចាំបាច់ឱ្យដូចគ្នាទៅនឹងការពិតជាក់ស្តែងទេ។ ពួកគេអាចបញ្ចូលព័ត៌មានដែលគេចងចាំ ២ ឬ ៣ (ឬច្រើន) ដាក់បញ្ចូលនៅក្នុងរឿងបាន។ ពួកគេអាចច្នៃប្រតិដ្ឋឡើងពីទីកន្លែងដែលពួកគេមិនបានចាំច្បាស់ ឬអ្វីដែលគេសង្ឃឹមថាអាចកើតឡើង។ រឿងរបស់ពួកគេគួរបង្ហាញអំពីការគិត និងអារម្មណ៍ចំពោះទីកន្លែង ឬព្រឹត្តិការណ៍នោះកាលពីនៅវ័យកុមារ។ អ្នកអានមិនដែលធ្លាប់បានទៅកន្លែងនោះទេកាលពីមុនមក ដូច្នេះពួកគេនឹងត្រូវប្រើព័ត៌មានលម្អិត ហើយច្បាស់លាស់ ដែលធ្វើឱ្យគេស្គាល់កន្លែងនោះកាន់តែច្បាស់លាស់។

គ្រូបញ្ជាក់ប្រាប់សិស្សថា ពួកគេត្រូវតែជ្រើសរើសទីកន្លែងមួយដែលពួកគេចង់និយាយ ហើយចែករំលែកព័ត៌មានពីកន្លែងនោះជាមួយអ្នកដទៃ។ ពួកគេមិនគួរជ្រើសរើសយកព័ត៌មានអ្វីដែលខ្លួនមិនចូលចិត្ត ឬមិនដឹងច្បាស់មកសរសេរនោះទេ។



### ៤.២.២ កំណាព្យ៖

កំណាព្យ គឺជាប្រភេទអត្ថបទអក្សរសិល្ប៍ដែលមានជាយូរលង់ណាស់មកហើយក្នុងប្រវត្តិអក្សរសិល្ប៍មនុស្សជាតិ។ កំណាព្យ មានចំណាប់ចុងចួនត្រឹមត្រូវទៅតាមក្បួនខ្នាត និងតាមចង្វាក់បទរបស់កំណាព្យនីមួយៗ។ អ្នកធ្លាប់សិក្សារួចមកហើយអំពីប្រភេទផ្សេងៗនៃបទកាព្យមូលដ្ឋានទាំង១៣របស់ខ្មែរយើងដូចជា បទកាកគតិ ព្រហ្មគីតិ ពំនោល បទពាក្យ៧ បទពាក្យ៨ ជាដើម។ ពេលនេះ អ្នកនឹងសិក្សាបន្ថែមទៀតអំពីកំណាព្យបទទ្វេមាត្រ។

កំណាព្យបទទ្វេមាត្រ គឺជាបទដែលកវីប្រើកាព្យមាត្រ២ ដែលមួយជាកាព្យមាត្របទមូលដ្ឋាន និងបន្ថែមកាព្យមាត្រថ្មីមួយទៀតលើបទមូលដ្ឋានទាំងអស់នោះ។

អត្ថប្រយោជន៍មួយទៀតនៃការនិពន្ធកំណាព្យ គឺសិស្សមានសេរីភាពបង្ហាញគំនិតផ្ទាល់ខ្លួនរបស់ពួកគេ។ ប្រភេទកំណាព្យមានច្រើនសម្រាប់សិស្សជ្រើសរើស ហើយគ្រូគួរបង្ហាញនូវប្រភេទកំណាព្យទាំងអស់នោះ ដើម្បីឱ្យសិស្សបានជ្រើសរើសតាមតម្រូវការផ្ទាល់ខ្លួន។ ឧទាហរណ៍គំរូសម្រាប់សកម្មភាពនិពន្ធកំណាព្យសូមមើលនៅក្នុងការតែងកំណាព្យដូចខាងក្រោម៖

ការតែងកំណាព្យបទទ្វេមាត្រ គោព័ទ្ធស្ទឹងពាក្យ៧

វត្ថុបំណង ៖ ឱ្យសិស្សរៀនសរសេរកំណាព្យបទទ្វេមាត្រ គោព័ទ្ធស្ទឹងពាក្យ៧

សម្ភារ ៖ ក្រដាស និងខ្មៅដៃ

រយៈពេល ៖ ១ម៉ោង

ដំណើរការ ៖ ពន្យល់សិស្សអំពីរង្វាស់កាព្យ ចំណាប់ចុងចួន ចង្វាក់ដូចបទពាក្យ៧ដែរ តែខុសពីបទពាក្យ៧ត្រង់ប្រើពាក្យផ្ទួន។




**ឧទាហរណ៍**

គង់កេរដំណែលតផៅពង្ស ពង្សយើងជាវង្សសាងប្រាង្គប្រា។
ប្រាសាទរាប់ពាន់លោកសាងទុក ទុកតទៅមុខតាងសារតារ

ដាដាក់ដាប់ធ្លាក់ល្អថ្លៃថ្លា ថ្លាថ្កើងអស្ចារ្យជូនតាយើង។

| របៀបចាប់ផ្ដើម |
| --- |
| បំផុសគំនិតទាក់ទងនឹងធម្មជាតិ បរិស្ថាន វប្បធម៌ សាលារៀន...។ |
| ជ្រើសរើសប្រធានបទដែលអ្នកចូលចិត្តរួចបំផុសគំនិត |
| រាប់ចំនួនព្យាង្គនៃឃ្លានីមួយៗ |
| ប្រមូលគំនិតសំខាន់ទាំងនោះមករំលេចជាព្យាង្គនិងបញ្ចូលក្នុងឃ្លាដោយគោរពតាមកាព្យមាត្រខាងលើ |
| |

ចំណងជើង________________________________

ល្បះទី១

________________________________________________________________

ល្បះទី២

________________________________________________________________

**សកម្មភាពអនុវត្តបន្ថែម៖ តែងកំណាព្យដោយប្រើចំណងជើងកាសែត**

វត្ថុបំណង ៖ លើកទឹកចិត្តសិស្សឱ្យស្វែងរកការបំផុសគំនិតពីប្រភពផ្សេងៗ

សម្ភារ ៖ កាសែត កន្ត្រៃ ការបិត

ពេលវេលា ៖ ១ម៉ោង

ដំណើរការ ៖

1. ឱ្យសិស្សធ្វើការជាបុគ្គល ជាគូ ឬជាក្រុម។
2. សូមប្រើប្រាស់អត្ថបទកាសែតដែលគ្រូផ្ដល់ឱ្យ សិស្សត្រូវអានចំណងជើងកាសែតទាំងនោះ។ តើពួកគេរកឃើញគំនិត ឬប្រធានបទណាមួយទេ នៅក្នុងចំណោមចំណងជើងកាសែតទាំងអស់នោះ?

   ឧ. នយោបាយ ឧក្រិដ្ឋកម្ម ស្នេហា គ្រោះធម្មជាតិ បរិស្ថាន។ល។ ចំណងជើងទាំងនេះអាចប្រើដើម្បីបញ្ចូលន័យរួមគ្នាសម្រាប់បង្កើតជាឃ្លាមួយ ដែលកើតឡើងនៅក្នុងពិភពលោកសព្វថ្ងៃ។
3. សិស្សជ្រើសរើសប្រធានបទ ឬគំនិតមួយ។
4. សិស្សជ្រើសរើសចំណងជើងកាសែតចំនួន ១០ ទៅ ១៥ ចំណងជើង។
5. សិស្សរៀបចំចំណងជើងតាមលំដាប់លំដោយបង្កើតឱ្យមានន័យ ឬល្បះពេញលេញមួយ។ សិស្សអាចប្រើចំណងជើងទាំងអស់ដែលពួកគេបានជ្រើសរើស ឬគ្រាន់តែយកចំណងជើងខ្លះមកប្រើតែប៉ុណ្ណោះ។ ពួកគេអាចបញ្ចូលគំនិតផ្សេងទៀតដែលគេរកបាន។

6. សិស្សសរសេរឬកាត់ចំណងជើងបិទនៅលើផ្ទាំងធំមួយ។
អត្ថបទនៅលើសន្លឹកក្រដាស ឬកាត់ជាបំណែកហើយបិតភ្ជាប់គ្នា។ បន្ថែមសញ្ញាវណ្ណយុត្តនៅចុងបញ្ចប់ នៃបន្ទាត់នីមួយៗដែលអ្នកគិតថាត្រឹមត្រូវ ដូចជា សញ្ញាខណ្ឌ សញ្ញាក្បៀស សញ្ញាសួរ ជាដើម។
7. ប្រសិនបើសិស្សច្រើនជាងម្នាក់ចង់កាត់បន្លយអត្ថបទចំណងជើងកាសែត សិស្សម្នាក់ក្នុងចំណោមពួកគេត្រូវសរសេរចូលនូវចំណងជើងទាំងនោះដាក់នៅលើក្រដាសសិន។
8. ប្រសិនបើពួកគេកាត់ហើយបិតភ្ជាប់គ្នារួច ពួកគេអាចបន្ថែមរូបថត គំនូរ ឬបំណកស្រាយផ្សេងៗពីកាសែត ឬតាមការច្នៃប្រតិដ្ឋរបស់ពួកគេ។
9. ដាក់ចំណងជើងនៃការបង្កើតរបស់ពួកគេ ហើយចែកឱ្យសមាជិកក្លឹបមើលទាំងអស់គ្នា។

**៤.២.៣ ទិនានុប្បវត្តិ**

សិស្សភាគច្រើនចង់សរសេរសកម្មភាពប្រចាំថ្ងៃ ក្រោមបរិយាកាសគ្មានការគំរាមកំហែង។ សំណេរបែបទិនានុប្បវត្តិគេអាចធ្វើបានទាំងក្នុង និងក្រៅម៉ោងសិក្សា ហើយវាមិនចាំបាច់ត្រូវការរចនាសម្ព័ន្ធច្បាស់លាស់ឡើយ។ ជាការពិតណាស់សិស្សអាចជ្រើសរើសប្រធានបទសរសេរដោយសេរីដែលគេអាចបកស្រាយ ឬឆ្លុះបញ្ចាំងផ្តែកលើបទពិសោធក្នុងជីវិត ដើម្បីពង្រីកបទពិសោធយល់ដឹងរបស់ពួកគេ។ ប្រសិនបើអ្នកចង់មើលសំណេរបែបទិនានុប្បវត្តិដែលមានរចនាសម្ព័ន្ធ សូមមើលគំរូនៅក្នុងសៀវភៅទិនានុប្បវត្តិ។



- បង្កើតទិនានុប្បវត្តិទៅជាកំណត់ហេតុការអាន – ឱ្យសិស្សបង្កើតសំណួរពីការអាន កត់ត្រាពីអារម្មណ៍របស់ពួកគេ ឬប្រតិកម្មចំពោះការជ្រើសរើស ឆ្លើយសំណួរដែលគ្រូសម្របសម្រួលបានដាក់ឱ្យ។ល។
- សួរសំណួរគួរឱ្យចាប់អារម្មណ៍ពីព្រឹត្តិការណ៍បច្ចុប្បន្ន ជីវិតនៅក្នុងសហគមន៍របស់ពួកគេ ឬជីវិតសាមញ្ញឱ្យសិស្សឆ្លើយ។ សូមឱ្យសិស្សបានគិតដោយការពិចារណា។
- ឱ្យសិស្សសរសេរត្រឡប់មកអ្នកវិញ ឬសរសេរឱ្យគ្នាទៅវិញទៅមក នៅពេលពួកគេទទួលបានការផ្តល់មតិយោបល់កែសម្រួលពីការងាររបស់គេ។
- ឱ្យសិស្សមានភាពសប្បាយរីករាយតាមរយៈការប្រៀបធៀប។ ឱ្យសិស្សបំពេញល្បះដូចខាងក្រោម៖ «ជីវិតប្រៀបដូចជា _________, ព្រោះ ___________.»
- លើកទឹកចិត្តសិស្សឱ្យសរសេរកំណាព្យ។

### ៤.២.៤ សំបុត៖

សិស្សសរសេរសំបុត្រជាលក្ខណៈក្រៅផ្លូវការទៅកាន់មិត្តភក្តិរបស់ពួកគេ ហើយសំបុត្រទាំងនោះអាចសរសេរពីប្រធានបទណាមួយក៏បាន។ អ្នកអាចបង្កើតជាសំណួរអំពីអំណាន ឬអំពីការនិពន្ធរបស់សិស្ស (ឧ. ប្រសិនបើពួកគេកំពុងសរសេររឿងខ្លីណាមួយ) ដើម្បីឱ្យយល់អំពីគំនិតរបស់សិស្សក្នុងការសរសេរ។ សិស្សអាចផ្លាស់ប្តូរសំបុត្រគ្នាទៅវិញទៅមក (អាចប្តូរជាមួយសិស្សនៅក្នុងថ្នាក់ ឬ សិស្សដទៃទៀត) អំពីប្រធានបទពាក់ព័ន្ធនឹងការរៀនក្នុងថ្នាក់ ឬពាក់ព័ន្ធនឹងជីវិតរស់នៅជាក់ស្តែងរបស់ពួកគេ ឬពាក់ព័ន្ធនឹងសាលារៀន។

### ៤.២.៥ ការបោះពុម្ព៖

សិស្សអាចចូលរួមជាមួយមិត្តភក្តិធ្វើកិច្ចការបោះពុម្ពស្នាដៃតែងនិពន្ធរបស់ពួកគេ ក្នុងព្រឹត្តិបត្រសាលារៀន។ ព្រឹត្តិបត្រគួរបញ្ចូលស្នាដៃនិពន្ធបែបច្នៃប្រតិដ្ឋ បំណកស្រាយបែបរូបភាព ឬសេចក្តីជូនដំណឹងពីព្រឹត្តិការណ៍សហគមន៍ដែលនឹងគ្រោងធ្វើនាពេលខាងមុខ។ ការបង្កើតព្រឹត្តិបត្រ គឺជាការផ្តល់ឱកាសឱ្យសិស្សមានភាពច្នៃប្រតិដ្ឋក្នុងការរៀបចំស្នាដៃតែងនិពន្ធរបស់ពួកគេ។ ការបង្កើតចំណងជើង និងប្លង់ព្រឹត្តិបត្រដោយខ្លួនឯង ជំរុញឱ្យពួកគេមានភាពម្ចាស់ការ។ ព្រឹត្តិបត្រសាលារៀន ផ្តល់ជាវេទិកាសម្រាប់សិស្សផ្សព្វផ្សាយការងាររបស់ពួកគេយ៉ាងទៀងទាត់ពេញមួយឆ្នាំសិក្សា។

ជម្រើសមួយទៀតក្នុងការបោះពុម្ពព្រឹត្តិបត្រ គឺការបោះពុម្ពសំណេរច្នៃប្រតិដ្ឋរបស់សមាជិកក្លឹបនៅចុងបញ្ចប់ត្រីមាស។ សិស្សអាចជ្រើសរើសលទ្ធផលកិច្ចការដែលពួកគេមានមោទនភាពបំផុត ដែលចង់ចែករំលែកទៅឱ្យមិត្តភក្តិរបស់ពួកគេ។ លទ្ធផលចុងក្រោយអាចរក្សាទុកនៅក្នុងបណ្ណាល័យ ឬបន្ទប់ក្លឹបមុខវិជ្ជាដើម្បីឱ្យសិស្សផ្សេងទៀតបានយល់ពីតម្លៃស្នាដៃ។

### ៤.២.៦ ការប្រជុំឱ្យតម្លៃស្នាដៃនិពន្ធ៖

កិច្ចប្រជុំនេះមានសារៈសំខាន់ដើម្បីលើកទឹកចិត្តសិស្សឱ្យចូលចិត្តអាន មិនមែនត្រឹមតែការឱ្យតម្លៃស្នាដៃរបស់អ្នកដទៃទេ ប៉ុន្តែជាការបណ្តុះទឹកចិត្តផងដែរ។ គ្រូអាចជ្រើសរើសអត្ថបទរឿងខ្លីៗឱ្យសិស្សអានដោយខ្លួនឯងនៅពេលណាមួយ ហើយបន្ទាប់មកទៀតពិភាក្សាគ្នានៅពេលជួបគ្នាក្នុងការប្រជុំក្លឹប ឬមួយក៏គ្រូអាចជ្រើសរើសរឿងខ្លីមួយ ឬកម្រងកំណាព្យមួយ ហើយសិស្សអាចផ្លាស់វេនគ្នាអានអត្ថបទនោះឱ្យលឺៗ ហើយពិភាក្សារួមគ្នា។ គំនិតសម្រាប់សំណួរពិភាក្សាមាននៅក្នុង**ទំព័រខាងក្រោម។** ម៉្យាងវិញទៀត គ្រូអាចជ្រើសរើសរឿងប្រលោមលោកបែបទំនើបមួយសម្រាប់សិស្សអាននៅជំពូកណាមួយ ហើយពិភាក្សានៅពេលជួបគ្នានៅក្នុងការរៀនក្លឹប។ វាក៏ជាគំនិតល្អផងដែរ ក្នុងការឱ្យសិស្សអានកិច្ចការរបស់សមាជិកក្លឹប បន្ទាប់មកផ្តល់ឱកាសឱ្យពួកគេផ្តល់ព័ត៌មានត្រឡប់។

ការអានសំណួរពិភាក្សាបង្កើនការយល់ដឹង

សំណួរខាងក្រោម អាចត្រូវបានដាក់បញ្ចូលទៅក្នុងរឿង ឬអត្ថបទប្រលោមលោកខ្លីៗ ហើយវាអាចឱ្យអ្នកចាប់ផ្តើមបង្កើតសំនួរពិភាក្សាបានយ៉ាងល្អសម្រាប់ការងារដែលបានដាក់ឱ្យធ្វើ។

- តើអ្វីជាលក្ខណៈដាច់ដោយឡែកពីគ្នាក្នុងការសរសេររឿង ឬសៀវភៅ ហើយតើលក្ខណៈនោះធ្វើឱ្យរឿងប្រសើរឡើងដូចម្តេច?

- តើគំនិតសំខាន់អ្វីដែលអ្នកនិពន្ធចង់បញ្ជាក់នៅក្នុងសាច់រឿងប្រលោមលោក? តើអ្នកគិតថា អ្នកនិពន្ធចង់ឱ្យអ្នកអានពីអ្វី?
- តើតួអង្គទំនងជាតួអង្គពិត និងគួរឱ្យជឿជាក់បានទេ? តើអ្នកអាចភ្ជាប់ទៅនឹងស្ថានភាពរបស់តួអង្គក្នុងរឿងបានទេ? តើរឿងនោះរំឭកពីខ្លួនអ្នក ឬអ្នកដទៃដែលអ្នកស្គាល់កម្រិតណា?
- តើតួអង្គបានផ្លាស់ប្តូរយ៉ាងដូចម្តេចនៅក្នុងរឿង? តើព្រឹត្តិការណ៍អ្វីដែលផ្តើមឱ្យមានការផ្លាស់ប្តូរទាំងនោះ?
- តើព្រឹត្តិការណ៍នៅក្នុងសៀវភៅទាំងនោះបានបង្ហាញភស្តុតាងអ្វីខ្លះអំពីទស្សនៈរបស់អ្នកនិពន្ធ?
- តើផ្នែកខ្លះនៃសៀវភៅធ្វើឱ្យអ្នកមិនយល់ស្របដែរឬទេ? ប្រសិនបើមាន ហេតុអ្វីបានជាអ្នកមានអារម្មណ៍បែបនេះ? តើរឿងនេះបានធ្វើឱ្យអ្នកទទួលចំណេះដឹងថ្មីៗ ដែលអ្នកមិនធ្លាប់គិតដល់ស្តីពីទិដ្ឋភាពជីវិតរស់នៅរបស់អ្នក ឬទេ?
- តើអ្វីដែលធ្វើឱ្យអ្នកសប្បាយរីករាយពីការអានរឿង ឬសៀវភៅនេះទេ?
- តើអ្នកធ្លាប់បានអានពីអ្វីនៅក្នុងរឿង ឬសៀវភៅដែលស្រដៀងសាច់រឿងនេះទេ?
- តើគំនិតសំខាន់ក្នុងរឿង ឬសៀវភៅនោះមានអ្វីខ្លះ?
- តើអ្នកគិតថាអ្នកនិពន្ធព្យាយាមបង្ហាញអ្វីនៅក្នុងរឿង ឬសៀវភៅនោះ?
- តើនរណាជាតួអង្គដែលអ្នកពេញចិត្ត? តើអ្នកមានការកោតសរសើរអ្វីខ្លះពីតួអង្គនោះ?
- ចូរពិចារណាលើតួអង្គសំខាន់ តើតួអង្គនោះជឿលើអ្វី? តើតួអង្គនោះចង់បានអ្វី?
- នៅចុងបញ្ចប់របស់រឿង ឬសៀវភៅ តើអ្នកមានសង្ឃឹមចំពោះតួអង្គ ឬទេ?
- តើអ្វីជាចំណុចខ្លាំងជាងគេនៅក្នុងរឿង ឬសៀវភៅនេះ៖ សាច់រឿង ឬការអភិវឌ្ឍតួអង្គក្នុងរឿង? ហេតុអ្វី? តើអ្នកគិតថា វាជាចេតនារបស់អ្នកនិពន្ធ ឬទេ?
- តើអ្នកធ្លាប់បានជួបប្រទះនឹងបញ្ហាអ្វីមួយដែលប្រហាក់ប្រហែលនឹងសាច់រឿងឬសៀវភៅនោះឬទេ?
- តើមានអ្វីខ្លះអំពីរឿង/សៀវភៅនេះ?
- តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះតួអង្គឯក?
- តើអ្វីជាទំនាក់ទំនងសំខាន់ជាងគេបំផុតនៅក្នុងរឿង ឬសៀវភៅនេះ?
- តើអ្វីដែលធ្វើឱ្យតួអង្គរងមានការចងចាំ?
- តើសាច់រឿងផ្នែកណាខ្លះដែលមានលក្ខណៈអប់រំល្អបំផុត?
- តើព្រឹត្តិការណ៍នៅក្នុងរឿង ឬសៀវភៅមានទំនាក់ទំនងទៅនឹងជីវិតពិតរបស់អ្នកឬទេ?
- តើគិតយ៉ាងដូចម្តេចចំពោះវិធីសរសេររបស់អ្នកនិពន្ធ?
- តើរឿងនោះវាអាចគួរឱ្យជឿជាក់បានទេ? តួអង្គគួរឱ្យជឿទុកចិត្តបានឬទេ?
- តើអ្នកឃើញកំហុស ឬគុណវិបត្តិនៅក្នុងសៀវភៅនេះដែរឬទេ?

**៤.២.៧ ការឆ្លុះបញ្ចាំងពីដំណើរទស្សនកិច្ច៖**

ក្លឹបនិពន្ធអាចធ្វើដំណើរទៅកាន់ទីកន្លែង ដែលគួរឱ្យចាប់អារម្មណ៍ណាមួយនៅក្នុងមូលដ្ឋាន ដើម្បីជាសកម្មភាពរស់រវើកមួយបណ្ដុះគំនិតសំណេរបែបច្នៃប្រតិដ្ឋ (ឧ. ប្រាសាទបុរាណ ទឹកជ្រោះ ឆ្នេរសមុទ្រ វាលខ្សាច់ ព្រៃភ្នំ) សិស្សអាចសរសេរអំពីបទពិសោធន៍ ដែលពួកគេជួបប្រទះជាទម្រង់បែបទិនានុប្បវត្តិ កំណាព្យ ប្រវត្តិផ្ទាល់ខ្លួន។ល។

**៤.២.៨ ការទំនាក់ទំនងរោងពុម្ពក្នុងមូលដ្ឋានសម្រាប់បោះពុម្ពអត្ថបទរឿងរបស់សិស្ស**

គ្រូសម្របសម្រួលក្លឹបអាចទំនាក់ទំនងជាមួយរោងពុម្ពក្នុងមូលដ្ឋាន ដើម្បីបោះពុម្ពសំណេរច្នៃប្រតិដ្ឋរបស់សិស្ស។

**៤.៣ ការប្រជុំឆ្លុះបញ្ចាំងដើម្បីវាយតម្លៃសកម្មភាពប្រចាំឆ្នាំ៖**

ការប្រជុំនេះអាចធ្វើឡើងបែបជាការធ្វើទស្សនកិច្ចទៅកាន់មូលដ្ឋាន ដើម្បីឆ្លុះបញ្ចាំងនូវបរិយាកាសល្អពីអ្វីដែលបានកើតឡើងនៅក្នុងក្លឹបរយៈពេលមួយឆ្នាំ។ សិស្សអាចចំណាយពេលដើម្បីអាននូវអ្វីដែលពួកគេពេញចិត្តពីម្នាក់ទៅម្នាក់ក្នុងរយៈពេលមួយឆ្នាំ។ គ្រូសម្របសម្រួលក្លឹបអាចចំណាយពេលដើម្បីរៀបចំការវាយតម្លៃខ្លីៗទៅលើក្លឹប ដើម្បីកែលម្អសម្រាប់ឆ្នាំក្រោយ។

ឧបសម្ព័ន្ធទី ១ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស

**សេចក្ដីផ្ដើម**

ការចូលរួមក្លឹបនិពន្ធគឺជាឱកាសមួយក្នុងការគិតតាមរយៈសកម្មភាពសំណេរច្នៃប្រតិដ្ឋ។ នេះគឺជាចំណុចមួយចំនួនដែលអ្នកគួរតែដឹង នៅមុនពេលអ្នកសម្រេចចិត្តថាតើត្រូវចូលរួមក្លឹប ឬមិនចូលរួម៖

- ***វត្ថុបំណង៖*** ផ្តល់បរិយាកាសជាវិជ្ជមាន និងគ្មានការគំរាមកំហែងចំពោះការអភិវឌ្ឍបំណិនសរសេរ។
- ***សកម្មភាព៖*** ការចុះតាមមូលដ្ឋាន ការសរសេរកំណត់ត្រាប្រចាំថ្ងៃ ការពិភាក្សាក្រុមអំពីរឿងប្រលោមលោកទំនើប ការបោះពុម្ពផ្សាយអត្ថបទតែងនិពន្ធ ការនិពន្ធកំណាព្យ។ល។
- ***ការវាយតម្លៃ៖*** ពុំមានការវាយតម្លៃ ឬការដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ។ សិស្សត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាព ពីព្រោះពួកគេចង់ធ្វើ មិនមែនដោយសារតែគេបង្ខំឡើយ។
- ***ការចូលរួម៖*** សមាសភាពក្លឹបចូលរួមដោយស្ម័គ្រចិត្ត ដោយស្ថិតក្នុងរង្វង់យ៉ាងច្រើនត្រឹម ១៥នាក់/ក្លឹប។
- ***ការប្រជុំ៖*** ការប្រជុំគួរធ្វើទៀងទាត់ (២សប្តាហ៍ម្តង) ដើម្បីពិភាក្សាផែនការសកម្មភាពបានគ្រោងទុក។ ការប្រជុំត្រូវធ្វើឡើងនៅក្រៅម៉ោងសិក្សា ឬពេលសាលាឈប់សម្រាក។

**សំណួរ**

សូមបញ្ជាក់ពីកម្រិតចំណាប់អារម្មណ៍របស់អ្នកក្នុងការចូលរួមក្លឹបនិពន្ធ ដោយគូសសញ្ញា (✓) នៅក្នុងប្រអប់ខាងក្រោមនេះ៖

☐ ខ្ញុំមិនចាប់អារម្មណ៍នឹងការចូលរួមក្លឹបនិពន្ធនេះទេ។

☐ ខ្ញុំចាប់អារម្មណ៍នឹងការចូលរួមក្លឹបនិពន្ធ ប៉ុន្តែខ្ញុំមិនប្រាកដថាមានពេលចូលរួមនោះទេ។

☐ខ្ញុំចាប់អារម្មណ៍ចូលរួមក្លឹបនិពន្ធខ្លាំងណាស់ ហើយខ្ញុំប្រាកដថាមានពេលវេលាគ្រប់គ្រាន់ចូលរួម។

ឧបសម្ព័ន្ធទី ២. ការបែងចែកភារកិច្ច

**១. ប្រធាន**

- រៀបចំការប្រជុំក្លឹប
- សម្របសម្រួលរៀបចំរបៀបវារៈសម្រាប់ការប្រជុំនីមួយៗ

- សម្របសម្រួលការប្រជុំ
- ជានាថាកន្លែងប្រជុំអាចប្រើប្រាស់បាន ដោយធ្វើការសម្របសម្រួលជាមួយនឹងនាយកសាលា
- ទំនាក់ទំនងជាមួយនឹងសមាជិកក្លឹប និងគណកម្មការសាលារៀន
- តាមដានការអនុវត្តផែនការសកម្មភាពក្រុម
- រាយការណ៍ពីបញ្ហានានាដល់គ្រូសម្របសម្រួលក្លឹប ប្រសិនបើមាន

២. អនុប្រធាន

- បំពេញតួនាទីជាប្រធានស្ដីទី នៅពេលប្រធានអវត្តមាន
- ជួយសម្របសម្រួលការប្រជុំ
- សរសេរកំណត់ហេតុប្រជុំ

៣. ហិរញ្ញិក

- ទទួលខុសត្រូវចំពោះថវិកាដែលបានផ្ដល់ឱ្យដោយសាលារៀន ឬទទួលបានពីប្រភពស្របច្បាប់ផ្សេងទៀត សម្រាប់ដំណើរការសកម្មភាពផ្សេងៗរបស់ក្លឹប។
- ថែរក្សាទុកកំណត់បញ្ជីចំណូលចំណាយថវិកាក្លឹប
- រៀបចំសំណើសុំថវិកា ឬចំណាយតាមការណែនាំរបស់គ្រូសម្របសម្រួលក្លឹប។

៤. ប្រធានក្រុម

- ផ្ដល់ភាពជាអ្នកដឹកនាំដល់ក្រុម
- ធ្វើរបាយការណ៍ក្នុងនាមតំណាងក្រុមជូនដល់ប្រធានក្លឹប ឬគ្រូសម្របសម្រួលក្លឹប
- ផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីប្រធានក្លឹប ឬគ្រូសម្របសម្រួលក្លឹបដល់សមាជិកក្រុម

៥. គ្រូសម្របសម្រួលក្លឹប

- ផ្ដល់ការណែនាំទូទៅពីគោលការណ៍ក្លឹបក្នុងការរៀបចំផែនការប្រជុំ ដឹកនាំការប្រជុំ ជ្រើសរើសប្រធានផ្នែកក្លឹប ជានាថាប្រធានក្លឹបអាចធ្វើការងារជាច្រើនបានដោយខ្លួនរបស់ពួកគេ។
- ផ្ដល់ការគាំទ្របច្ចេកទេសពីបញ្ហាទាក់ទងនឹងក្លឹបនិពន្ធ (សម្របសម្រួលសម្ភាររូបវន្ត តាមដានដំណើរការប្រើប្រាស់សម្ភារ។ល។)
- តំណាងឱ្យក្លឹបក្នុងពេលដំណើរការរៀបចំថវិកា និងត្រួតពិនិត្យការប្រើប្រាស់ថវិកាក្លឹប។
- សម្របសម្រួលសកម្មភាពផ្សេងៗដូចជា ការរៀបចំផែនការ និងការធ្វើដំណើរចុះមូលដ្ឋាន។
- សម្របសម្រួលការទំនាក់ទំនងរវាងក្លឹប និងរដ្ឋបាលសាលាសម្រាប់គោលបំណងផ្សេងៗ ដូចជាការប្រើប្រាស់បណ្ណាល័យសម្រាប់ការប្រជុំជាដើម

ឧបសម្ព័ន្ធទី ៣ ការកំណត់ផែនការ

ត្រីមាសទី ១៖

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| 1. | | | | | | | | | | | | |
| 2. | | | | | | | | | | | | |
| 3. | | | | | | | | | | | | |
| 4. | | | | | | | | | | | | |
| 5. | | | | | | | | | | | | |
| 6. | | | | | | | | | | | | |
| 7. | | | | | | | | | | | | |
| 8. | | | | | | | | | | | | |
| 9. | | | | | | | | | | | | |
| 10. | | | | | | | | | | | | |
| 11. | | | | | | | | | | | | |
| 12. | | | | | | | | | | | | |
| 13. | | | | | | | | | | | | |
| 14. | | | | | | | | | | | | |

ត្រីមាសទី ២៖

| សកម្មភាព | កុម្ភៈ | | | | មីនា | | | | មេសា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
| 1. | | | | | | | | | | | | |
| 2. | | | | | | | | | | | | |
| 3. | | | | | | | | | | | | |
| 4. | | | | | | | | | | | | |
| 5. | | | | | | | | | | | | |
| 6. | | | | | | | | | | | | |
| 7. | | | | | | | | | | | | |
| 8. | | | | | | | | | | | | |
| 9. | | | | | | | | | | | | |
| 10. | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 11. | | | | | | | | | | | | |
| 12. | | | | | | | | | | | | |
| 13. | | | | | | | | | | | | |
| 14. | | | | | | | | | | | | |

ឧបសម្ព័ន្ធទី ៤៖ ការកំណត់ថវិកា

| ការចំណាយ | ឯកត្តា | ចំនួន |
|---|---|---|
| 1. ក្រដាសផ្ទាំងធំ | ១ kg x ៨,០០០៛/kg | ៨,០០០៛ |
| 2. ហ្វឺតសរសេរក្ដារខៀន | ១ ប្រអប់ x ១០,០០០៛/ប្រអប់ | ២០,០០០៛ |
| 3. ក្រដាសពណ៌ | ២ រ៉ាម x ១៦,០០០៛/រ៉ាម | ៣២,០០០៛ |
| 4. ការបោះពុម្ពសំណេរ | -- | ៤០,០០០៛ |
| 5. <u>ទស្សនកិច្ចសិក្សា</u><br>អាហារថ្ងៃត្រង់៖<br>រថយន្តឈ្នួល៖<br>ម៉ាស៊ីនថតរូប៖ | <br>១៥ នាក់ x ៤,០០០៛/ នាក់<br>១០០,០០០៛/ថ្ងៃ x ១ ថ្ងៃ<br>ម៉ាស៊ីនថតផ្ទាល់ខ្លួន ឬទូរស័ព្ទដៃ | <br>៦០,០០០៛<br>១០០,០០០៛<br>--------------<br>១៦០,០០០៛ |
| 6. <u>ការចុះមូលដ្ឋាន #</u>2៖<br>អាហារថ្ងៃត្រង់៖<br>រថយន្តឈ្នួល៖<br>ម៉ាស៊ីនថតរូប៖ | <br>15 នាក់ x $1/នាក់<br>$25/ ថ្ងៃ x 1 ថ្ងៃ<br>ម៉ាស៊ីនថតផ្ទាល់ខ្លួន ឬទូរស័ព្ទដៃ | <br>៦០,០០០៛<br>១០០,០០០៛<br>--------------<br>១៦០,០០០៛ |
| សរុប | | ៤២០,០០០ រៀល |